ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..............................................................

# សុន្ទរកថាស្វាគមន៍
## លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ប្រជាពលរដ្ឋឃុំឈូក
## ស្ថិតក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

ថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥

សូមគោរព

- ឯកឧត្តម នួន ផារ័ត្ន អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ
- ឯកឧត្តម លោកជំទាវ លោក-លោកស្រី ក្រុមការងារថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក
- លោក លោកស្រី លោកតា លោកយាយ អ៊ុំ ពូ មីង បងប្អូនប្រជាពលរដ្ឋ ដែលមានវត្តមាន នាពេលនេះ!

ថ្ងៃនេះ ខ្ញុំមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលទូទៅបងប្អូននិយមហៅថាបណ្ណកម្មសិទ្ធិ ឬប្លង់រឹង ជូនដល់ប្រជាពលរដ្ឋនៅឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាពេលនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងកម្មវិធីនាព្រឹកនេះ។ ខ្ញុំសូមអរគុណចំពោះលោកប្រធានមន្ទីរសុរិយោដី ខេត្តកំពង់ធំ ចំពោះរបាយការណ៍យ៉ាងក្បោះក្បាយអំពីសកម្មភាពចាប់តាំងពីចុះវាស់វែង រហូតដល់ការផ្តល់ជូននូវបណ្ណកម្មសិទ្ធិនៅថ្ងៃនេះ និងមតិស្វាគមន៍យ៉ាងកក់ក្តៅរបស់ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ដែលបានថ្លែងមុននេះបន្តិច។

ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំសូមពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខប្រកបដោយក្តីនឹករឭកពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលលោកតែងតែគិតគូរពីសុខទុក្ខរបស់ប្រជាជនទាំងអស់នៅទូទាំងប្រទេស ជាពិសេសនៅខេត្តកំពង់ធំ។ វីរៈភាព និងស្នាដៃជាច្រើនរបស់ថ្នាក់ដឹកនាំទាំងអស់ដែលបានបន្សល់ទុកត្រូវបានអ្នកបន្តវេនជំនាន់ក្រោយចងចាំ និងដឹងគុណជានិច្ច ចំពោះសមិទ្ធផលទាំងឡាយដែលជាមូលដ្ឋានដ៏រឹងមាំនាំមកនូវការអភិវឌ្ឍរីកចម្រើន ជាពិសេស តាមរយៈគោលនយោបាយ ឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានសុខសន្តិភាព



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

មានការអភិវឌ្ឍលើគ្រប់វិស័យ និងមានកិត្តិនាមល្បីរន្ទឺទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ។

បន្ថែមលើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ពិសេសជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ការធានានូវភាពជាម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យត្រូវបានចាត់ទុកជាការងារសំខាន់មួយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នេះ។ ខ្ញុំក៏សូមលើកឡើងនូវប្រសាសន៍សំខាន់ៗរបស់ **សម្តេចមហាបវរធិបតី** ក្នុងពិធីប្រកាសបញ្ចប់ការវាស់វែងដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងពិធីចែកបណ្ណកម្មសិទ្ធិដីធ្លី" នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤ កន្លងទៅនេះ ដូចតទៅ៖

- ការបែងចែក ការវាស់វែង ការរៀបចំចុះបញ្ជីក្បាលដី និងការប្រគល់បណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ គឺជាសករាជថ្មីនៃការជំរុញការអភិវឌ្ឍប្រទេសជាតិរបស់យើង និងផ្តល់ផលដល់ប្រជាជនផ្ទាល់។ ការផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋតកូនតចៅ ជាផលជាក់ស្តែងជូនប្រជាពលរដ្ឋ។ ការផ្តល់កម្មសិទ្ធិ ដីធ្លី មិនមែនផ្តល់ត្រឹមតែលោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនប្រជាពលរដ្ឋនោះទេ គឺផ្តល់ជាតំណ ព្រោះដីប្រគល់ឱ្យហើយ រដ្ឋអត់យកពីបងប្អូនប្រជាពលរដ្ឋវិញទេ ហើយបងប្អូនអាចផ្ទេរបន្តបាន មិនដូចកាលជំនាន់ ប៉ុល ពត ដែលពុំមានកម្មសិទ្ធិដីធ្លីនោះទេ។ ការចែកបណ្ណកម្មសិទ្ធិដីធ្លី គឺជានិមិត្តរូបនៃលទ្ធផលជាក់ស្តែងជូនប្រជាពលរដ្ឋយើងរហូត តកូនតចៅ។
- ដី មានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋយើងគ្រប់គ្នា មិនថាអ្នកក្រុង មិនថាអ្នកជនបទនោះទេ។ ដី គឺជាមូលដ្ឋាននៃលំនៅដ្ឋានសម្រាប់អ្នកទីក្រុង ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ មិនត្រឹមតែជាលំនៅដ្ឋានទេ ថែមទាំងជាមូលដ្ឋានសម្រាប់បង្កបង្កើនផលចិញ្ចឹមជីវិត ធ្វើស្រែចម្ការ សម្រាប់ចិញ្ចឹមកូនចៅផងដែរ។ ដីក៏ជាមូលដ្ឋានទ្រព្យដែលអាចលក់ដូរ ផ្ទេរបន្តទៅឱ្យកូនចៅជំនាន់ក្រោយ ចែកទ្រព្យ ជាដើម។ ដូច្នេះ ដីពិតជាមានសារៈសំខាន់ណាស់សម្រាប់យើងគ្រប់គ្នា។
- ផលដែលទទួលបានក្នុងថ្ងៃនេះ គឺដោយសារ **សន្តិភាព** ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាកំពូលស្ថាបនិក និងបិតាសន្តិភាពរបស់ប្រទេសកម្ពុជា។ ដូច្នេះយើងបានបញ្ចប់សង្គ្រាម យើងលែងមានតំបន់រដ្ឋបាលគ្រប់គ្រងដោយ ២ ឬ ៣ភាគីកម្លាំងប្រដាប់អាវុធទៀតហើយ គឺមានរដ្ឋាភិបាលតែមួយគត់ ដែលបង្កលក្ខណៈឱ្យយើងអាចវាស់វែងដីទាំងអស់ទូទាំងប្រទេស ចុះបញ្ជីស្តង់ដារតែមួយ ដោយច្បាប់តែមួយ ដើម្បីធានានូវភាពរឹងមាំសម្រាប់ប្រជាពលរដ្ឋគ្រប់កន្លែងទាំងអស់។
- ការផ្តល់កម្មសិទ្ធិដីធ្លីជាឯកជនជូនប្រជាពលរដ្ឋត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ១៩៨៩ តាមរយៈការផ្តួចផ្តើមរបស់ **សម្តេចតេជោ** យើងបានធ្វើការកែទម្រង់សេដ្ឋកិច្ចពីសេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារ។ ពេលនោះ ចាប់ផ្តើមពីការផ្តល់កម្មសិទ្ធិឯកជនដីធ្លីជូនប្រជាពលរដ្ឋ។

យើងបានធ្វើជិត ៤០ឆ្នាំមកហើយ។ សន្តិភាពបានបង្កើតឱ្យមានសកម្មភាពសេដ្ឋកិច្ច ពេលណាមានសកម្មភាពសេដ្ឋកិច្ច ប្រជាពលរដ្ឋក៏មានជីវភាពរស់នៅបានប្រសើរឡើងដែរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអបអរសាទរយ៉ាងក្រៃលែងចំពោះ លោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិចំនួន ៤ នៃឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលនឹងទទួលបានបណ្ណកម្មសិទ្ធិនាពេលបន្តិចទៀតនេះ។ ភូមិទាំងបួននឹងទទួលបានបណ្ណសរុបមានចំនួន **១.៣៩០បណ្ណ** ក្នុងនោះ ភូមិអន្លង់ស្លែងទទួលបាន **៥៣២បណ្ណ** ភូមិបឹងខ្វែក **៣៦៩បណ្ណ** ភូមិអន្លង់ខ្មុំ **២៩១បណ្ណ** និងភូមិកំពីងតាគង់ **១៩៨បណ្ណ**។ ក្រោយពីទទួលបានបណ្ណកម្មសិទ្ធិនេះ សូមលោកតា លោកយាយ អ៊ំ ពូ មីង និងបងប្អូនទាំងអស់រក្សាទុកដោយប្រយ័ត្នប្រយែងឱ្យបានល្អ ចៀសវាងការទុករាយប៉ាយ ដែល បង្កឱ្យមានការទក់ រហែក ប្រឡាក់ ឬកណ្តៀរកោរ កណ្តុរកាត់ ជាដើម។

លោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនជាទីស្រឡាញ់ បណ្ណកម្មសិទ្ធិនេះ ជាឯកសារផ្លូវការដ៏ចាំបាច់សម្រាប់ទទួលស្គាល់ភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ដែលជាទូទៅត្រូវបានចាត់ជាផ្នែកដ៏សំខាន់នៃទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារនីមួយៗ។ ទន្ទឹមនេះ ឯកសារនេះមិនត្រឹមតែជាមូលដ្ឋានសម្រាប់បែងចែកមរតក តកូនតចៅនោះប៉ុណ្ណោះទេ តែក៏ជាឯកសារចាំបាច់បំផុតសម្រាប់ធានាការខ្ចីឥណទានសម្រាប់បង្កើតអាជីវកម្ម និងបម្រើដល់ការងារបង្កបង្កើនផលកសិកម្មផងដែរ។ ទាក់ទងនឹងចំណុចនេះ ខ្ញុំសូមអំពាវនាវដល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុទាំងអស់ សូមមានការប្រុងប្រយ័ត្នខ្ពស់ និងចៀសវាងការទទួលកម្ចីពីក្រុមទុច្ចរិតក្រៅច្បាប់។ កន្លងទៅថ្មីៗនេះ ខ្ញុំក៏បានធ្វើដំណើរទស្សនកិច្ចតាមបណ្តាខេត្តចំនួន៥ រួមមាន ខេត្តកំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគិរី និងព្រះវិហារ ដើម្បីស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន ព្រមទាំងបានជួបពិភាក្សាការងារជាមួយអភិបាលនៃគណៈអភិបាលខេត្តទាំងនេះផងដែរ។ ជាទូទៅ ឯកឧត្តមអភិបាលខេត្តខាងលើ បានបញ្ជាក់ពីការរួមចំណែករបស់សេវាហិរញ្ញវត្ថុផ្លូវការ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននាពេលកន្លងមក ប៉ុន្តែទន្ទឹមនេះ ពួកគាត់ក៏បានលើកឡើងពីបញ្ហាទាក់ទងនឹងវត្តមានក្រុមចងការប្រាក់ខុសច្បាប់ និងកម្ចីតាមអនឡាញខុសច្បាប់ផងដែរ។ ក្រុមខុសច្បាប់ទាំងនេះធ្វើប្រតិបត្តិការតាមភូមិ-ឃុំ ដោយមានការរៀបចំរចនាសម្ព័ន្ធការងារច្បាស់លាស់ និងផ្តល់កម្ចីមានលក្ខណ្ឌងាយៗ តែគិតអត្រាការប្រាក់ខ្ពស់ហួសហេតុ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ ហើយនៅពេលអ្នកខ្ចីមានបញ្ហាសងត្រឡប់ ក្រុមខុសច្បាប់ទាំងនេះតែងបំភិតបំភ័យ គំរាមកំហែង ធ្វើឱ្យប៉ះពាល់សុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងអាចនាំឱ្យមានការវាយតម្លៃមិនល្អចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ថែមទៀតផង។ ដូច្នេះ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវលោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនជាទីស្រឡាញ់ទាំងអស់ សូមចៀសវាងដាច់ខាតក្នុងការខ្ចីប្រាក់ពី

ក្រុមខុសច្បាប់ទាំងនេះ ដើម្បីចៀសផុតពីការកេងចំណេញលើសលប់ ដែលនាំឱ្យកើតមានបំណុលវ័ណ្ឌក ហើយប្រសិនបើមានការចាំបាច់ត្រូវប្រើប្រាស់ប្រាក់កម្ចី សូមព្យាយាមនិងស្វែងរកកម្ចីផ្លូវការពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។ ខ្ញុំក៏សូមយកឱកាសនេះ ស្នើសុំកិច្ចសហការពី ឯកឧត្តម នួន ផារ័ត្ន អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សូមជួយបង្ការនិងចាត់វិធានការហ្មត់ចត់លើក្រុមផ្តល់កម្ចីខុសច្បាប់ និងកម្ចីអនឡាញខុសច្បាប់ ដើម្បីបង្ការហានិភ័យ និងធានាបានភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនប្រជាពលរដ្ឋទាំងអស់!**

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀតចំពោះឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ជាពិសេស មន្ទីរសុរិយោដីខេត្តកំពង់ធំ ដែលបានខិតខំជំរុញការងារចេញបណ្ណកម្មសិទ្ធិនេះបានទាន់ពេលវេលា ហើយអាចចែកជូនដល់លោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនប្រជាពលរដ្ឋនាពេលនេះ។ ខ្ញុំសូមសំណូមពរដល់ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងមន្ទីរសុរិយោដី នៅខេត្តកំពង់ធំ មេត្តាបន្តបញ្ចប់ការងារចុះបញ្ជីដីធ្លី នៅក្នុងស្រុកប្រាសាទសំបូរ ឱ្យបានចប់សព្វគ្រប់នៅឆ្នាំ២០២៥ និងបន្តចេញបណ្ណកម្មសិទ្ធិសម្គាល់ម្ចាស់អចលនវត្ថុឱ្យបានឆាប់ស្របតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។ នេះគឺជាការចែកលើកទី១ សម្រាប់ឃុំឈូក ហើយខ្ញុំសង្ឃឹមថា ឃុំចំនួន ៤ផ្សេងទៀត ក្នុងស្រុកប្រាសាទសំបូរ ក៏នឹងទទួលបានបណ្ណកម្មសិទ្ធិនេះជាបន្តបន្ទាប់ទៀតផងដែរ។ ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីខ្មែរដែលនឹងឈានចូលមកដល់ឆាប់ៗនេះ រដ្ឋបាលខេត្តកំពង់ធំនឹងរៀបចំសង្ក្រាន្តកំពង់ធំ ដូច្នេះ សូមបងប្អូនអ្នកស្រុកប្រាសាទសំបូរទាំងអស់ចូលរួមឱ្យបានគ្រប់ៗគ្នា ក្រោមម្លប់នៃសន្តិភាព។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ដែលជាគណៈអធិបតី ព្រមទាំងលោកតា លោកយាយ អ៊ំ ពូ មីង បងប្អូនប្រជាពលរដ្ឋទាំងអស់ដែលមានវត្តមាននាពេលនេះ សូមមានសុខភាពល្អ កម្លាំងមាំមួន និងសូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**